មនសិការខ្មែរ
Moneaksekar Khmer

ថ្ងៃ ច័ន្ទ ទី ២១ ខែ សីហា ឆ្នាំ ២០០៦

# លោក សម រង្ស៊ី អំពាវនាវឱ្យ FBI ស្វែងរកជួប ហេង ពៅ ដើម្បីបញ្ជាក់ការពិត ហេង ពៅ រំលឹកពីរឿងបោកគ្រាប់បែកនៅគណបក្ស សឺន សាន និងការចាប់អាវុធ ៣៦ គីឡូក្រាម

ដោយ : ហង្ស ឧត្តម

នៅទីក្រុងឡុងប៊ិច នៃសហរដ្ឋអាមេរិក លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីដែលជាគណបក្សជំទាស់តែមួយគត់នៅក្នុងប្រទេសកម្ពុជា បានមានប្រសាសន៍ប្រាប់បណ្ដាញព័ត៌មានសហរដ្ឋអាមេរិកថា លោកនឹងជម្រាបមន្ត្រីអាមេរិកាំង និងបងប្អូនខ្មែរនៅសហរដ្ឋអាមេរិកពីព្រឹត្តិការណ៍ចុងក្រោយនេះ គឺមានការលាតត្រដាងនូវអំពើឧក្រិដ្ឋតាមរយៈ *ហេង ពៅ* បានបញ្ចេញព័ត៌មានខ្លះ ធ្វើឱ្យមតិជាតិ និងអន្តរជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយសារ ការរំដើបរំជួលនៅក្នុងជួរអ្នកដឹកនាំនៅប្រទេសកម្ពុជា។

លោក *សម រង្ស៊ី* បានមានប្រសាសន៍បន្តទៀតថា "*ប្រសិនបើអ្វីដែល ហេង ពៅ និយាយជាការពិតនោះនឹងឆ្លុះបង្ហាញថាប្រទេសកម្ពុជាយើងមានរដ្ឋភេរវករ និងរដ្ឋម៉ាហ្វីយ៉ា។ នេះគឺជារឿងធ្ងន់ធ្ងរណាស់ ព្រោះរដ្ឋភេរវករដោយសារថា មេដឹកនាំកំពូលចូលរួមក្នុងការសម្លាប់មនុស្ស សម្លាប់អ្នកប្រឆាំងនយោបាយផង ហើយសម្លាប់រឿងផ្ទៃក្នុង មកពីការប្រកួតប្រជែងគ្នាផង*"។

ក្នុងនោះមេដឹកនាំគណបក្សសមរង្ស៊ីដ៏មានប្រិយភាព បានគូសបញ្ជាក់ថា ទាក់ទិននឹងរដ្ឋម៉ាហ្វីយ៉ា គឺមេដឹកនាំកំពូលនៅប្រទេសកម្ពុជាជាប់ពាក់ព័ន្ធ ក្នុងការជួញដូរគ្រឿងញៀន។ ចំពោះរឿងនេះ យើងប្រៀបធៀបទៅគឺមិនខុសពីរឿង "*ពាលស៊ីពាល*" ដូច្នោះដែរ "*តែខ្ញុំមិនដឹងថា អ្នកណាល្អជាងអ្នកណាទេ ខ្ញុំប្រើពាក្យពាលស៊ីពាល ប្រហែលជាឆ្លុះបញ្ចាំងការពិតហើយ*"។

គួររំលឹកថា នៅក្នុងបទសម្ភាសន៍ផ្ដាច់មុខរបស់អ្នកស្រី *ស៊ីលវ៉ៃន់ប៉ាស្តែរ* នៃទស្សនាវដ្ដី L' Express គឺអ្នកស្រីបានកំណត់ថា "*ហេង ពៅ គឺជាគ្រាប់បែកកម្រិតមោ៉ងផ្ទុះសម្រាប់ប្រព័ន្ធគ្រប់គ្រង ហ៊ុន សែន*"។ *ហេង ពៅ* បាននិយាយប្រាប់អ្នកស្រី *ស៊ីល្វែន ប៉ាស្តែរ* ថា នៅឆ្នាំ ១៩៩៥ *ហ៊ុន សែន* ចង់បញ្ឈប់មិនឱ្យមានការធ្វើបាតុកម្មដើម្បីលទ្ធិប្រជាធិបតេយ្យទេ ហើយនៅចុងឆ្នាំនោះ *ហ៊ុន សែន* បានបើកកិច្ចប្រជុំមួយនៅឯផ្ទះរបស់គាត់ទួលក្រសាំង ដោយមានការចូលរួមពី *ហុក ឡុងឌី*។ *ហ៊ុន សែន* ក៏បានហៅ *ហេង ពៅ* ឱ្យទៅចូលរួមនៅក្នុងកិច្ចប្រជុំនោះដែរ។

*ហេង ពៅ* បានបញ្ជាក់តាមការផ្សាយ នៃទស្សនាវដ្ដី L' Express ថា "*ខ្ញុំស្គាល់អ្នកខ្លះដែលចូលរួមក្នុងកិច្ចប្រជុំនោះ ហើយ ខ្ញុំមានភស្តុតាងនូវអ្វីដែលខ្ញុំបាននិយាយពីឆ្នាំគប់គ្រាប់បែកប្រឆាំងនឹងគណបក្សរបស់លោក សឺន សាន។ ខ្ញុំអាចនិយាយថាអ្នកណាជាអ្នកគប់គ្រាប់បែក ? គឺជាមនុស្សរបស់ ម៉ក់ ជីតូ ដែលបច្ចុប្បន្ននេះ ធ្វើជាប្រធានប៉ូលិសព្រហ្មទណ្ឌក្រសួងមហាផ្ទៃ*"។

*ហេង ពៅ* បានបន្តទៀតថា កាលពីខែមីនា ឆ្នាំ១៩៩៧ រូបមន្តដដែលនោះ ត្រូវបានយកទៅប្រើប្រឆាំងនឹងសមាជិកគណបក្សសមរង្ស៊ី និងប្រធានគណបក្សសមរង្ស៊ី ដែលប្រមូលផ្ដុំគ្នានៅមុខរដ្ឋសភាជាតិ។ *ហេង ពៅ* បានអះអាងថា "*ខ្ញុំទើបតែមកដល់កន្លែងបាតុកម្មប៉ុន្មាននាទីប៉ុណ្ណោះ ស្រាប់តែគ្រាប់បែកផ្ទុះឡើង។ ភ្លាមៗនោះ ខ្ញុំឃើញមនុស្ស៤នាក់រត់គេចខ្លួនទៅកាន់ផ្ទះនាយករដ្ឋមន្ត្រី ហ៊ុន សែន*"។

ជនជាប់ចោទ *ហេង ពៅ* -អតីតអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអតីតទីប្រឹក្សានាយករដ្ឋមន្ត្រី *ហ៊ុន សែន* នៅបានលាតត្រដាងពីការចាប់បានអាវុធចំនួន៣៦គីឡូក្រាមទៀត

អាភៀនចំនួន៣៦គីឡូក្រាមទៀត ដែលក្នុងនោះ *ហេង ពៅ* បាន គូសបញ្ជាក់ថា *"នៅឆ្នាំ២០០១ ខ្ញុំបានទទួលព័ត៌មានសម្ងាត់ ពីជនលាក់មុខម្នាក់និយាយថា វរសេនីយ៍ទោ ង៉ឿ សម្បត្តិ ជាមនុស្សជំនិតរបស់ឧត្តមសេនីយ៍ សៅ សុខា និងឧត្តមសេនីយ៍ ដុម ហាក់ មានជាប់ពាក់ព័ន្ធក្នុងរឿងជួញដូរអាភៀន"*។

*ហេង ពៅ* បានរៀបរាប់ថា *"ក្រោយមកបន្ទាប់ពីមានការស៊ើបអង្កេត ខ្ញុំក៏បានទៅផ្ទះគាត់នៅសង្កាត់ទួលគោក ក្នុងក្រុងភ្នំពេញ ហើយចាប់បានអាភៀនចំនួន៣៦គីឡូក្រាម។ វរសេនីយ៍ទោ ង៉ឿ សម្បត្តិ ត្រូវបានចាប់ខ្លួននៅនឹងកន្លែង តែឧត្តមសេនីយ៍ ដុម ហាក់ ដែលស្ថិតនៅទីនោះ បានគេចខ្លួនពីកន្លែងកើតហេតុ"*។

*ហេង ពៅ* បានសង្កត់ធ្ងន់ថា យើងមានបំណងតាមដេញចាប់ឧត្តមសេនីយ៍ *ដុម ហាក់* តែ *ហ៊ុន សែន* បានបញ្ឈប់យើង ដោយបញ្ជាឱ្យឈប់ចាប់ *ដុម ហាក់* និងមិនឱ្យធ្វើការស៊ើបអង្កេតពី *ដុម ហាក់* អ្វីទាំងអស់។ ដូច្នេះយើងត្រូវតែឈប់ដេញតាម និងបញ្ឈប់ការស៊ើបអង្កេតតាមបញ្ជានាយករដ្ឋមន្ត្រី *ហ៊ុន សែន*។

*ហេង ពៅ* បានសម្តែងនូវការហួសចិត្តថា ជំនួសដល់ការផ្តន្ទាទោសតាមផ្លូវច្បាប់ ទៅលើឧត្តមសេនីយ៍ *ដុម ហាក់* នោះ គឺមជ្ឈដ្ឋាននានាបានបង្ហាញពីការភ្ញាក់ផ្អើលបំផុត ចំពោះទង្វើ *ហ៊ុន សែន* ដែលបានតម្លើងឋានន្តរស័ក្តិឱ្យ *ដុម ហាក់* ដល់ទៅផ្កាយ៣ ក្រោយពីមានរឿងផ្ទុះឡើង ប្រហែលមួយខែប៉ុណ្ណោះ។ ប៉ុន្តែ សម្រាប់ *ង៉ឿ សម្បត្តិ* ត្រូវបាន គេសម្លាប់នៅក្នុងគុក។ *"ហ៊ុន សែន បានប្រាប់ខ្ញុំថា មិនត្រូវខ្លាំងដៃពេកទេ អំពីរឿងជួញដូរគ្រឿងញៀននោះ"*។

នៅក្នុង សេចក្តីថ្លែងការណ៍អនាមិកចំនួន៩ទំព័រ *ហេង ពៅ* បានអធិប្បាយពីរឿងទំនាស់ជាមួយឧត្តមសេនីយ៍ *សៅ សុខា* ដែរ ដោយជនជាប់ចោទពីបទឧក្រិដ្ឋម្នាក់នេះបាននិយាយថា មិនយូរប៉ុន្មាន គេមានការងារមួយដែលរៀបចំឡើងដោយ *ហុក ឡងឌី* សម្រាប់ឧត្តមសេនីយ៍ទាំងអស់។ ហើយ *សៅ សុខា* ក៏មានវត្តមាននៅក្នុងទីនោះដែរ។

ពេលជួបគ្នា *"សៅ សុខា បានកោតសរសើរខ្ញុំយ៉ាងច្រើន ចំពោះការងារនោះ និងចង់ឱ្យខ្ញុំងាកមកជិតស្និទ្ធជាមួយគាត់។ ពេលនោះ សៅ សុខា បាននិយាយថា បើយើងរួមដៃគ្នា យើងអាចធ្វើអ្វីៗបានទាំងអស់នៅស្រុកខ្មែរ។ សៅ សុខា* បានបន្តទៀតថា *"អ្វីតែមួយគត់នោះ គឺជំហររបស់ខ្ញុំ អំពីជំនួញគ្រឿងញៀន"*។ *សៅ សុខា* បានសុំឱ្យ *ហេង ពៅ* ឈប់ស៊ើបអង្កេត អំពីជំនួញគ្រឿងញៀនដោយអះអាងថា គ្រឿងញៀនពុំបង្កបញ្ហាអ្វីដល់កម្ពុជាទេ។

ប៉ុន្តែ *ហេង ពៅ* បានបដិសេធថា មិនយល់ស្របតាមសម្តី *សៅ សុខា* ទើបគាត់នេះខឹង ហើយគំរាមថា *"បើខ្ញុំនៅតែបន្តធ្វើការស៊ើបអង្កេតពីការរត់ពន្ធគ្រឿងញៀនទៀត សៅ សុខា នឹងប្រើដាវរបស់គាត់ សម្លាប់ខ្ញុំ"*។ អ្នកដទៃទៀតដែលបានឃើញហេតុការណ៍ ប្រឈមមុខដាក់គ្នា រវាង *ហេង ពៅ* និង *សៅ សុខា* នោះ ក៏នាំគ្នាមកឃាត់ ទើបស្ងប់ស្ងាត់វិញទៅ។

*ហេង ពៅ* បាននិយាយពីរឿងទំនាស់ជាមួយ *ហុក ឡងឌី* ដោយសារតែ *ហេង ពៅ* មិនគោរពតាមបទបញ្ជារហូត មានការចងគំនុំយ៉ាងជ្រាលជ្រៅបំផុត។ *ហេង ពៅ* បានឆ្លុះបញ្ចាំងថា *"នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៥ ហុក ឡងឌី បានហៅពួកស្នងការប៉ូលិស, អភិបាលក្រុង និងមន្ត្រីជាន់ខ្ពស់ នៃខណ្ឌទាំង៧ ទៅប្រជុំនៅសាលាក្រុងភ្នំពេញ។ ហុក ឡងឌី គាត់បានបើកបង្ហាញនូវអ្វីដែលអាចធ្វើទៅបាន ដើម្បីដកហូតឋានន្តរស័ក្តិខ្ញុំ ក្នុងរវាង៣ខែទៀត។ គាត់ត្រូវតែសម្រេចនូវគោលដៅនេះ តែបើមិនសម្រេចវិញគាត់ត្រូវតែបកស័ក្តិផ្កាយ៤របស់គាត់គ្រវាត់ចោល"*។

ក្រោយអង្គប្រជុំនៅសាលាក្រុងភ្នំពេញនោះ *ហេង ពៅ* បាននិយាយថា *"ខ្ញុំបានទៅរកនាយករដ្ឋមន្ត្រីឱ្យជួយធ្វើអន្តរាគមន៍ តែនាយករដ្ឋមន្ត្រីបានប្រាប់ខ្ញុំថា កុំបារម្ភអ្វី។ ហើយថាគាត់គ្មានផ្លូវទុកឱ្យ ហុក ឡងឌី ដកខ្ញុំចេញពីតំណែងបានឡើយ។ នាយករដ្ឋមន្ត្រីបាននិយាយទៀតថា ខ្លួនគាត់ផ្ទាល់ក៏មានបញ្ហាជាមួយ ហុក ឡងឌី ដែរ"*។

ទាក់ទិនទៅនឹងសេចក្តីថ្លែង

ការណ៍៩ទំព័រ និងបទសម្ភាសន៍ផ្តាច់មុខរបស់ទស្សនាវដ្តី L' Express ដែលផ្សព្វផ្សាយពីបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ តាមការអះអាងរបស់ *ហេង ពៅ* នោះត្រូវបានលោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីមានប្រសាសន៍អំពាវនាវជាសាធារណៈ ទៅរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនថា *ហេង ពៅ* គឺជាសាក្សីមួយយ៉ាងសំខាន់ ដែលគួរតែរដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏ដូចជាភ្នាក់ងារ FBI ត្រូវតែស្វែងរកជួប *ហេង ពៅ* ដាច់ខាត ដើម្បីបញ្ជាក់ការពិតពីហេតុការណ៍ឧក្រិដ្ឋដែលបានកើតឡើង នៅក្នុងប្រទេសកម្ពុជាកន្លងមកនោះ ។

តាមពិតទៅ ការរៀបរាប់របស់ *ហេង ពៅ* ទាំងប៉ុន្មានទោះជាពិត ឬមិនពិតក្តី ក៏ពុំមានប្រភពណាមួយហ៊ានអះអាងដែរ ។ ប៉ុន្តែយោងតាមការតាមដានរបស់អ្នកសង្កេតការណ៍ គេបានវាយតម្លៃថា សម្តី *ហេង ពៅ* មិនត្រូវមួយរយភាគរយទេ គឺមានចំណុចខ្លះ *ហេង ពៅ* និយាយ យកត្រូវតែម្នាក់ឯង ដូចជាករណីឃាតកបាញ់សម្លាប់លោក *ជា វិជ្ជា* ប្រធានសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជាជាដើម ។

ព្រោះកាលណោះ *ស៊ឹម ហុង* មេប៉េអឹមក្រុងភ្នំពេញ ក៏បានបើកការស៊ើបអង្កេតរកឃើញអ្នកផ្ញើសារគម្រាមសម្លាប់លោក *ជា វិជ្ជា* និងមានការចាប់ខ្លួនជនម្នាក់ឈ្មោះ *ម៉ែន រតនា* ហើយជននេះ បានឆ្លើយបំភ្លឺក្នុងសន្និសីទសារព័ត៌មានមួយនៅក្នុងឆ្នាំ២០០៤ បានឆ្លើយដាក់លោក *អេង ឆៃអ៊ាង* ថែមទៀតផង ។ ប៉ុន្តែលោក *អេង ឆៃអ៊ាង* បានឱ្យមេធាវីរបស់គាត់រៀបចំពាក្យបណ្តឹងមួយ ប្តឹង *ស៊ឹម ហុង* ទៅតុលាការក្រុងភ្នំពេញ តែត្រូវគេផ្អឹបទុកចោល រហូតមកដល់សព្វថ្ងៃ ។

មិនតែប៉ុណ្ណោះ *ម៉ែន វឌ្ឍនា* ដែលត្រូវប៉េអឹមក្រុងភ្នំពេញចាប់ឃាត់ខ្លួននោះ ក៏កំពុងដើរលេងយ៉ាងរីភើយ នៅមាត់ទន្លេដែរ ។ ដែលស្ទើនឹងមានន័យថាមុននឹងលេងល្បែងឃាតកសិប្បនិម្មិត *ប៊ិន សំណាង* និង *សុខ សំអឿន* គឺ *ស៊ឹម ហុង* លេងជាមួយ *ម៉ែន វឌ្ឍនា* មួយក្បាច់មុន ដើម្បីទក់ហាងឆេងសិន ។ លុះដល់ដឹងថាទៅមិនរួច ក៏គេងាកមកលេងល្បែងបិទមុខជាមួយ *ប៊ិន សំណាង* និង *សុខ សំអឿន* តែម្តងទៅ ។

ដូច្នេះ បើចង់ឱ្យមានយុត្តិធម៌ចំពោះសពលោក *ជា វិជ្ជា* នោះ រដ្ឋាភិបាលក៏ត្រូវតែដាក់ការស៊ើបអង្កេតពីសកម្មភាពរបស់ *ស៊ឹម ហុង* ប៉េអឹមក្រុងភ្នំពេញផងដែរ ព្រោះមានគេសង្ស័យថា *ហេង ពៅ* និង *ស៊ឹម ហុង* អាចដឹងរឿងច្រើនពីករណីឃាតកម្មលើរូបលោក *ជា វិជ្ជា* នោះ ។

ជាមួយនេះដែរ មានការសន្និដ្ឋានពីគ្រប់មជ្ឈដ្ឋានថា *ហេង ពៅ* ប្រហែលជាទៅដល់ប្រទេសទី៣បាត់ទៅហើយ ។ ព្រោះការចេញសេចក្តីថ្លែងការណ៍អនាមិកចំនួន៩ទំព័រ និងការធ្វើសម្ភាសន៍ផ្តាច់មុខជាមួយទស្សនាវដ្តី L' Express នាពេលថ្មីៗនេះ គឺ *ហេង ពៅ* មិនអាចធ្វើនៅប្រទេសសិង្ហបុរីបានទេ ។

ប៉ុន្តែ *កែវ រ៉ាន់ថន* អនុប្រធានទី១ នៃការិយាល័យប៉ូលិសអន្តរជាតិក្រសួងមហាផ្ទៃ នៅតែអះអាងថា *ហេង ពៅ* ស្ថិតនៅក្នុងប្រទេសសិង្ហបុរីនៅឡើយទេ ។ ហើយប៉ូលិសសិង្ហបុរី បានសន្យាថា នឹងធ្វើការចាប់ខ្លួន *ហេង ពៅ* តែមិនបានបញ្ជាក់អំពីការបញ្ជូនខ្លួន *ហេង ពៅ* មកកាត់ទោសនៅប្រទេសកម្ពុជាវិញឡើយ ៕